**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តឧត្តរមានជ័យ**
សំណុំរឿងព្រហ្មទណ្ឌលេខ ១៦៦
ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២១
សាលក្រមលេខ **៤២** (**ក**) **១**
ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១

**តាមនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តឧត្តរមានជ័យ**

បានបើកសវនាការជាសាធារណៈ នៅសាលជម្រះក្តីនៃសាលាដំបូងខេត្តឧត្តរមានជ័យនាថ្ងៃពុធ ១រោច ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ពុទ្ធសករាជ ២៥៦៥ ត្រូវនឹងថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង៨កន្លះព្រឹក មានសមាសភាពដូចតទៅ៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

ឯកឧត្តម [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក [redacted] ចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

ឯកឧត្តម [redacted] ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តឧត្តរមានជ័យ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តឧត្តរមានជ័យ

**ដើម្បីជំនុំជម្រះលើ**

ទណ្ឌិតឈ្មោះ [redacted] ជា ភេទប្រុស អាយុ ២៧ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅ [redacted] ខេត្តតាកែវ ទីលំនៅបច្ចុប្បន្ននៅភូមិត្រពាំងប្រាសាទ ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ប្រពន្ធឈ្មោះ [redacted] អន ហៅ ម៉ី មានកូនចំនួន ០១នាក់ ឪពុកឈ្មោះ [redacted] រ៉ាន់ (រ) ម្តាយឈ្មោះ [redacted] ទូច (រ) ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការចំនួន៣ដង។

-មេធាវីការពារសិទ្ធិជនជាប់ចោទលោក [redacted] មានការិយាល័យនៅផ្ទះលេខ ១០សេ ផ្លូវលេខ១០៥ សង្កាត់ទួលសង្កែទី១ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ។

ប្រវត្តិទោស៖

-ជាប់ចោទពីបទ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិអូរឈើទាលជ្រុំ ឃុំអូរស្វាយ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិ



Scanned with CamScanner

ត្យគ្រឿងញៀន ដែលផ្តន្ទាទោសដោយសាលក្រមព្រហ្មណ្ឌលេខ ១២ "ង" ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តឧត្តរមានជ័យ។

-ជាប់ចោទពីបទ ជួញដូរ និង ប្រើប្រាស់ដោយខុសច្បាប់នូវសារជាតុញៀន ប្រព្រឹត្តនៅភូមិត្រពាំងប្រាសាទ ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលផ្តន្ទាទោសដោយសាលក្រព្រហ្មទណ្ឌលេខ ១៧ "ង" ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តឧត្តរមានជ័យ។

-ជាប់ចោទពីបទ ជួញដូរដោយខុសច្បាប់នូវសារជាតុញៀន ប្រព្រឹត្តនៅភូមិអូរជញ្ជៀន ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលផ្តន្ទាទោសដោយសាលក្រមព្រហ្មទណ្ឌលេខ ៩ (ឃ) ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តឧត្តរមានជ័យ។

-បានឃើញ ពាក្យសុំស្រូបទោសបញ្ចូនគ្នា ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២១ របស់ទណ្ឌិតឈ្មោះ វ៉ាន់ ដា។

-បានឃើញ របាយការណ៍លេខ ៤៦២ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ របស់ពន្ធនាគារខេត្តឧត្តរមានជ័យ។

## អង្គហេតុនៃរឿងមានដូចតទៅ៖

ទណ្ឌិតឈ្មោះ [redacted] ដា បានស្នើសុំឱ្យស្រូបទោសបញ្ចូលគ្នា រវាងសាលក្រមព្រហ្មទណ្ឌស្ថាពរលេខ ០៩ "ឃ" ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៩ និងសាលក្រមព្រហ្មទណ្ឌស្ថាពរលេខ ១២ "ង" ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩ ចូលសាលក្រមព្រហ្មទណ្ឌលេខ ១៧ (ង) ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តឧត្តរមានជ័យ។ ដោយឆ្លងកាត់តាមការអប់រំ ក្នុងពន្ធនាគារខេត្តឧត្តរមានជ័យ នាពេលកន្លងមកទណ្ឌិតឈ្មោះ [redacted] ដា បានដឹងពីកំហុសរបស់ខ្លួន និងបានគោរពប្រតិបត្តិយ៉ាងហ្មត់ចត់ត្រឹមត្រូវតាមបទបញ្ជាផ្ទៃក្នុងរបស់ពន្ធនាគារ និង បានយកចិត្តទុកដាក់បំពេញការងារពលកម្ម យ៉ាងសកម្មទៀងទាត់ ដែលជាគំរូដល់ទណ្ឌិតដទៃទៀត។ ទណ្ឌមានស្មារតីរលឹក ខិតខំលត់ដំកែប្រែខ្លួនបានល្អ និងបានប្តេជ្ញាចិត្ត ខិតខំរៀនសូត្រអប់រំ ឱ្យក្លាយជាពលរដ្ឋសុចរិត មានប្រយោជន៍ដល់សង្គមជាតិ។

## ពេលសវនាការ

-ទណ្ឌិតឈ្មោះ [redacted] ដា បានឆ្លើយនាពេលសវនាការថា៖ មូលហេតុដែលខ្លួនសុំស្រូបទោស ដើម្បីឆាប់បានចេញពីពន្ធនាគារ ដើម្បីទៅរស់នៅជាមួយឪពុកម្តាយវិញ ខ្លួនបានដឹងនូវកំហុសដែលខ្លួនបានប្រព្រឹត្ត នៅក្នុងពន្ធនាគារខ្លួនបានកសាងខ្លួនក្លាយជាបុគ្គលល្អដែលជាគម្រូដល់ទណ្ឌិតដទៃទៀតផងដែរ។ ឪពុកម្តាយរបស់ខ្លួនមានវ័យចាស់ជរា គ្មានអ្នកនៅមើលថែរក្សាដូច្នេះខ្លួនចង់ប្រើប្រាស់ពេលវេលាចុងក្រោយ ដើម្បីធ្វើជាកូនល្អមើលថែរក្សាអ្នកមានគុណ និងធ្វើជាពលរដ្ឋល្អក្នុងសង្គមជាតិសាជាថ្មីម្តងទៀត។

-ក្រឡាបញ្ជីអានសាលក្រមព្រហ្មទណ្ឌលេខ ០៩ "ឃ" ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តឧត្តរមានជ័យ។

-ក្រឡាបញ្ជីអានសាលក្រមព្រហ្មទណ្ឌលេខ ១២ "ង" ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តឧត្តរមានជ័យ។

-ក្រឡាបញ្ជីអានសាលក្រមព្រហ្មទណ្ឌលេខ ១៧ "ង" ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តឧត្តរមានជ័យ។

-ក្រឡាបញ្ជីអានលិខិតរបស់ពន្ធនាគារខេត្តឧត្តរមានជ័យ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីសកម្មភាពរបស់ទណ្ឌិតឈ្មោះ [redacted] ដា នាពេលដែលកំពុងជាប់ឃុំ។

**-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា៖** ក្រោយពីបានពិនិត្យសំណុំរឿង ស្តាប់ការសួរដេញដោលចម្លើយទណ្ឌិត និងអំណានឯកសារនានាក្នុងសំណុំរឿងនាពេលសវនាការ ឃើញថាទណ្ឌិតនេះសុំស្រូបទោសបីបទល្មើសដែលមានសាលក្រមស្ថាពររួចហើយ ដូច្នេះតុលាការចាត់ការតាមនីតិវិធី។

**-មេធាវីការពារសិទ្ធិឱ្យទណ្ឌិតបានធ្វើសេចក្តីសន្និដ្ឋានការពារថា៖** សាលក្រមលេខ០៩ "ឃ" ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៩ នឹង សាលក្រមព្រហ្មទណ្ឌលេខ ១២ "ង" ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩ និងសាលក្រមព្រហ្មទណ្ឌលេខ ១៧ "ង" ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តឧត្តរមានជ័យ ពិតជាបានចូលស្ថាពររួចហើយ និង មានលិខិតបញ្ជាក់ពីពន្ធនាគារថាទណ្ឌិតឈ្មោះ [redacted] ដា បានដឹងខ្លួន ដូច្នេះក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យទណ្ឌិតឈ្មោះ [redacted] ដា ស្នើសុំតុលាការមេត្តាសូមស្រូបទោសដល់កូនក្តីរបស់ខ្លួនតាមនីតិវិធីច្បាប់។

-ទណ្ឌិតឈ្មោះ [redacted] ដា និយាយសម្តីចុងក្រោយថា៖ ខ្លួនសុំឱ្យតុលាការមេត្តាស្រូបទោស និងបន្ធូរបន្ថយទោសដល់រូបខ្លួន។

-ក្រោយពីបានស្តាប់ចម្លើយរបស់ទណ្ឌិត

-ក្រោយពីបានស្តាប់អំណានឯកសារនានានៅក្នុងសំណុំរឿង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារទណ្ឌិត

-ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ទណ្ឌិត

-ក្រោយពីបានពិនិត្យភស្តុតាងនានាក្នុងសំណុំរឿង

**ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ ហើយ**

**សាលាដំបូងខេត្តឧត្តរមានជ័យ**

**យល់ឃើញថា**

១-យោងតាមបទបញ្ញត្តិនៃមាត្រា ៥០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងថា៖ "ពាក្យសុំស្រូបទោសបញ្ចូលគ្នា ត្រូវលើកនៅមុខតុលាការដែលបានសម្រេចចុងក្រោយគេ។ តុលាការនេះទទួលបណ្តឹង

តាមពាក្យបណ្ដឹងរបស់អយ្យការ ឬរបស់ភាគីពាក់ព័ន្ធ។ តុលាការសម្រេចក្នុងពេលសវនាការជាសាធារណៈ ក្រោយពីបានស្ដាប់អយ្យការភាគីពាក់ព័ន្ធ និងជាយថាហេតុមេធាវីរបស់ភាគី"។

២-តាមសាលក្រមព្រហ្មទណ្ឌលេខ ០៩ "ឃ" ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តឧត្តរមានជ័យ ពីបទ**ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិអូរជញ្ជៀន ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន សម្រេចផ្ដន្ទាទោសកំណត់ ០២ (ពីរ) ឆ្នាំ តែទោសនេះត្រូវអនុវត្តជាប់ពន្ធនាគារចំនួន ១៨ (ដប់ប្រាំបី) ខែ ទោសសល់ពីនេះអនុវត្តទោសព្យួរ គឺបានចូលជាស្ថាពរកាលពីថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៩ រួចហើយ ចំណែកសាលក្រមព្រហ្មទណ្ឌលេខ **១២ "ង"** ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តឧត្តរមានជ័យ ពីបទ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិអូរឈើទាលជ្រំ ឃុំអូរស្វាយ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន បានសម្រេចផ្ដន្ទាទោសកំណត់ ០៥ (ប្រាំ) ឆ្នាំ បានចូលជាស្ថាពរកាលពីថ្ងៃទី០២ ខែមករា ឆ្នាំ២០២០ និងសាលក្រមព្រហ្មទណ្ឌលេខ ១៧ (ង) ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តឧត្តរមានជ័យ ពីបទ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិត្រពាំងប្រាសាទ ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន បានសម្រេចផ្ដន្ទាទោសកំណត់ ០៦ (ប្រាំមួយ) ឆ្នាំ ក៏បានចូលជាស្ថាពរកាលពីថ្ងៃទី០២ ខែមករា ឆ្នាំ២០២០ ទៀតផងដែរ។

២-នៅក្នុងសំណុំរឿងព្រហ្មទណ្ឌនេះ ទណ្ឌិតឈ្មោះ [redacted] **ជា** បានប្ដឹងសុំឱ្យតុលាការប្រកាសស្រូបទោសលើសាលក្រមព្រហ្មទណ្ឌស្ថាពរចំនួន ០៣ សាលក្រមបញ្ចូលគ្នា ដើម្បីបន្ធូរបន្ថយនៃការអនុវត្តទណ្ឌកម្មរបស់ខ្លួន។

៣-តាមមាត្រា ១៣៨ កថាខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌបានចែងថា "នៅក្នុងពេលចោទប្រកាន់ដាច់ពីគ្នា កាលបើជនជាប់ចោទត្រូវបានរកឃើញថា មានពិរុទ្ធពីបទល្មើសច្រើន ទោសដែលត្រូវប្រកាស ត្រូវអនុវត្តត្រួតគ្នានៅក្នុងព្រំដែននៃអតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ។ ប៉ុន្តែតុលាការចុងក្រោយដែលត្រូវសម្រេចអាចប្រកាសឱ្យអនុវត្តទោសស្រូបបញ្ចូលគ្នាទាំងមូល ឬ មួយផ្នែកនៃទោសដែលមានប្រភេទដូចគ្នា។"

៤-យោងតាមចំណុចទី១, ចំណុចទី២ និងចំណុចទី៣ ខាងលើ ឃើញថា ទណ្ឌិតឈ្មោះ [redacted] **ជា** ត្រូវបានតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារ នៅក្នុងសាលក្រមចំនួនបីដាច់ដោយឡែកពីគ្នាដែលសាលក្រមទាំងបីនេះសុទ្ធតែបានចូលស្ថាពររួចហើយដែរនោះ ហើយទោសដែលតុលាការបាន

ប្រកាសចំពោះមុខទណ្ឌិត គឺជាបទឧក្រិដ្ឋ និងបទមជ្ឈិម ដែលត្រូវដាក់ទោសពន្ធនាគារពី ១៨ (ដប់ប្រាំបី)ខែ, ០៥ (ប្រាំ) ឆ្នាំ និង ០៦ (ប្រាំមួយ) ឆ្នាំ ដោយសាលក្រមទាំងបីនោះបានសម្រេចផ្តន្ទាទណ្ឌិតឈ្មោះ [redacted] ដា ដាក់ទោសពន្ធនាគារតែ ០៦ (ប្រាំមួយ) ឆ្នាំ ដែលការប្រកាសទោសចុងក្រោយនេះ គឺដាក់ក្នុងកំរិតអប្បរមានៃទោស ហេតុដូច្នេះគប្បីតុលាការសម្រេចស្រូបទោសរបស់ទណ្ឌិតឈ្មោះ [redacted] ដា ដើម្បីអាចឱ្យទណ្ឌិតកែប្រែខ្លួនឆាប់បានវិលចូលទៅរួមរស់នៅក្នុងសង្គមវិញ។

**ហេតុដូច្នេះសម្រេច**

១-សម្រេចស្រូបទោសសាលក្រមព្រហ្មទណ្ឌលេខ ០៩ "ឃ" ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៩ សាលក្រមព្រហ្មទណ្ឌលេខ ១២ "ង" ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩ និងសាលក្រមព្រហ្មទណ្ឌលេខ ១៧ "ង" ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩ បញ្ចូលគ្នាដោយផ្តន្ទាទោសទណ្ឌិតឈ្មោះ [redacted] ដា ដាក់ពន្ធនាគារកំណត់រយៈ ០៦ (ប្រាំមួយ) ឆ្នាំ គិតពីថ្ងៃឃុំខ្លួន។

២.សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃព្រហស្បតិ៍ ១៥កើត ខែអស្សុជ ឆ្នាំឆ្លូវ ព.ស២៥៦៥ ត្រូវនឹងថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១ ចំពោះមុខទណ្ឌិតឈ្មោះ [redacted] ដា។ ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] |